# តេស្តសើស្បែក

# ម៉ែនធូសំរាប់រោគរបេង

**Mantoux Skin Test for Tuberculosis, Cambodian**

Developed by the
Minnesota Department of Health,
Tuberculosis Prevention and Control Program
August 2002 phone: (612) 676-5414

This is one in a series of four patient education pamphlets that addresses TB to be used in various clinical situations.

## ជំងឺនិងការកើតមានរោគរបេង

> រោគរបេងអាចព្យាបាលឱ្យជាស្រឡះដោយប្រើថ្នាំ

រោគរបេង(TB) គឺជាជំងឺធ្ងន់មួយ ដែលបណ្ដាលមកពីមេរោគដែលបង្កើនឡើងនៅក្នុងខ្លួន ហើយធ្វើឱ្យខ្ញូចជាលិកា។ ជំងឺភាគច្រើនគឺវាប៉ះពាល់ដល់សួត។ រោគរបេងគឺឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតតាមខ្យល់អាកាស។ រោគ របេងអាចព្យាបាលឱ្យជាដាច់ស្រឡះដោយប្រើថ្នាំ។

សញ្ញានិងអាការរោគនៃជំងឺរបេងនេះ
មានរួមបញ្ចូលដោយ:

- ការក្អកជាច្រើន
- ការក្អកធ្លាក់កំហាក
- ការក្អកធ្លាក់ឈាម
- ឈឺដើមទ្រូងនៅពេលអ្នកក្អក
- ស្គម ស្រកទម្ងន់
- គ្រុនក្ដៅ
- បែកញើសច្រើននៅពេលយប់
- ឈឺត្រង់កន្លែងដែលមានជំងឺ

នៅពេលអ្នកណាមួយដែលមានជំងឺរបេងនៅក្នុងសួត ក្អក កណ្ដាស់ ឬស្រែក មេរោគរបេងអាចរាយសាយក្នុងខ្យល់។ អ្នកដទៃអាចដកដង្ហើមដោយមេរោគរបេងចូលក្នុងសួតរបស់គេ។ នេះគេហៅថា ការកើតមានរោគរបេង។

អ្នកណាមួយមានការកើតរោគរបេង:
- គេមិនមានអាការរោគជាសញ្ញាឱ្យដឹងទេ
- គេមិនដឹងខ្លួនថាឈឺទេ
- គេមិនចម្លងមេរោគទៅអ្នកដទៃឡើយ

មេរោគរបេង អាចរស់នៅក្នុងខ្លួនបានជាច្រើនឆ្នាំដោយមិនធ្វើឱ្យមានជំងឺឡើយ។ បើអ្នកណាមួយមានការកើតរោគរបេង មិនបានព្យាបាលដោយប្រើថ្នាំទេ គេអាចនឹងទៅជាឈឺដោយជំងឺរបេង។ បន្ទាប់មក មេរោគរបេងអាចឆ្លងទៅអ្នកដទៃ។

អ្នកអាចមានការកើតរោគរបេង បើអ្នកធ្លាប់រស់នៅជិតអ្នកណាមួយមានជំងឺរបេង(ទោះបីជាអ្នកមិនដឹងថាគេមានជំងឺរបេងក៏ដោយ)។ មនុស្សយើងមិនដឹងថា តើគេមានការកើតរោគរបេងឬទេ លុះត្រាតែគេបានធ្វើតេស្តទើបដឹង។

## តេស្តសើស្បែកម៉ែនធូ (Mantoux)

តេស្តម៉ែនធូធ្វើនៅលើស្បែក គឺជាមធ្យោបាយល្អមួយសំរាប់ឱ្យដឹងថា អ្នកមានការកើតរោគរបេងឬទេ។ តេស្តនេះច្រើនធ្វើនៅលើដៃ។ កូនម្ជុលតូចមួយសំរាប់ប្រើចាក់ថ្នាំធ្វើតេស្ត (ដែលហៅថាទូប៉ាគូលីន) នៅក្រោមស្បែក។ កន្ទួល ឬពំណក់ក្រហមមួយអាចកើតមានឡើង។ អ្នកត្រូវតែទៅជួបមន្ទីរព្យាបាលក្នុងរយៈពេល២ ទៅ៣ថ្ងៃក្រោយ ពេលធ្វើតេស្តដើម្បីពិនិត្យមើលថា តើអ្នកមានការកើតរោគ របេងឬទេ។ អ្នកប្រហែលជាត្រូវទៅធ្វើតេស្តម្តងទៀតនៅពេលក្រោយ ដើម្បីធ្វើការបញ្ជាក់ឱ្យឃើញបានច្បាស់លាស់។

> តេស្តសើស្បែកម៉ែនធូអាចឱ្យដឹងថាអ្នកមានការកើតរោគរបេងឬមិនមាន

ទោះបីជាអ្នកបានចាក់ថ្នាំBCG (Bacille Calmette-Guerin) ការពារកាលពីមុនក៏ដោយអ្នកនៅតែអាចធ្វើតេស្តសើស្បែកម៉ែនធូបានដែរ។ ថ្នាំBCG នេះមិនមានប្រតិកម្មអ្វីចំពោះការធ្វើតេស្តម៉ែនធូទេ និងមិនមែនការពារអ្នកពីរោគរបេងជានិច្ចនោះទេ។

បើតេស្តសើស្បែកម៉ែនធូ បញ្ជាក់ថាអ្នកមានការកើតរោគរបេង ឬបើអ្នកមានអាការ រោគនៃជំងឺរបេង អ្នកនឹងត្រូវតែថតអិចរេនៅលើដើមទ្រូង សំរាប់មើលថា តើសួតរបស់អ្នកមានខូចខាតដោយសារ មេរោគរបេងឬទេ។ តេស្តផ្សេងៗទៀត ប្រហែលជាត្រូវ ធ្វើបន្ថែម សំរាប់ពិនិត្យថា តើអ្នកគួរប្រើថ្នាំឬទេ។

## ការព្យាបាលសំរាប់ការកើតមានរោគរបេង

គេប្រហែលជាស្នើឱ្យអ្នកលេបថ្នាំសំរាប់ការពារកុំឱ្យអ្នកទៅជាកើតជំងឺរបេងនៅពេលអនាគត។ ជាធម្មតា គេសុំឱ្យ អ្នកប្រើថ្នាំ បើអ្នក:

- នៅជិតជាមួយអ្នកដែលមានជំងឺរបេង
- មានថតអិចរេនៅលើទ្រូងដែលបញ្ជាក់ថាធ្លាប់មានជំងឺរបេងពីមុនមក
- មានលក្ខណៈជំងឺដែលអាចបង្កើនទូវការបង្កើតជំងឺរបេងរបស់អ្នក

## ការព្យាបាលសំរាប់ជំងឺរបេង

មានថ្នាំដែលសំរាប់ព្យាបាលជំងឺររេបង។ ជំងឺរបេងអាចព្យាបាលឱ្យបានជាស្រឡះដោយប្រើថ្នាំតាមសំបុត្រពេទ្យបញ្ជា។